៧៨

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

សំណុំរឿងព្រហ្មទណ្ឌលេខ ២៨៩

ចុះថ្ងៃទី ៣១ ខែមករា ឆ្នាំ២០១១

សាលក្រមព្រហ្មទណ្ឌ

លេខ ១១៨ ក្រ៦ -ជ- ចុះថ្ងៃទី

០៦ ខែតុលា ឆ្នាំ២០១១

## គោរពនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅសាលសវនាការនៃសាលាដំបូងរាជធានីភ្នំពេញនាថ្ងៃទីម្ភៃមួយ ខែកញ្ញា ឆ្នាំពីរពាន់ដប់មួយ វេលាម៉ោងប្រាំបួនព្រឹក ដោយមានសមាសភាពដូចតទៅ៖

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោកស្រី [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ជាព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ជាក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

### ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខ ២៨៩ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១១ ដែលមាន៖

១-ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ២៩ឆ្នាំ ជនជាតិខ្មែរ មុខរបរគ្មាន មានទីកន្លែងកំណើតនៅសង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទីលំនៅមុនពេលចាប់ខ្លួនផ្ទះ [redacted] សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] នៅរស់ ទោសពីមុនគ្មាន ។

ត្រូវចោទពីបទៈ **ការចាប់ជំរិតហិង្សានិងបង្ខាំងដោយខុសច្បាប់ដោយមានស្ថានទម្ងន់(ប្លន់ដោយមានប្រើអាវុធទ្រព្យសម្បត្តិ)និងបទកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត** ប្រព្រឹត្តនៅមុខសាកលវិទ្យាល័យជាតិគ្រប់គ្រង សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ និងសង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២៧និង២៨ ខែមករា ឆ្នាំ២០១១ បទល្មើសដែលមានចែងក្នុងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៥៣, ២៥៤ និងមាត្រា២៥០ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

ដែលមានលោក [redacted] មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ។

៧៥

Scanned by CamScanner

២-ជនរងគ្រោះឈ្មោះ[redacted] សោភា ភេទស្រី សញ្ជាតិខ្មែរ អាយុ១៩ឆ្នាំ កើតនៅថ្ងៃទី០៧-៣-១៩៩២ ទីកន្លែងកំណើតសង្កាត់មិត្តភាព ខណ្ឌ៧មករា ក្រុងភ្នំពេញ មានទីលំនៅសព្វថ្ងៃផ្ទះ[redacted] ខណ្ឌ៧មករា រាជធានីភ្នំពេញ មុខរបរសិស្ស នៅលីវ ម្តាយឈ្មោះ [redacted] ឪពុកឈ្មោះ[redacted] ។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ១៩៩ អ.យ.យ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ៣៩៨ អ.យ.យ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ៨១៨ ជ.ជ.រ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១១ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

## អង្គហេតុដែលបណ្តាលឲ្យមានការចោទប្រកាន់ ៖

កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០១១ វេលាម៉ោង១៣:៣០នាទី ដោយមានគម្រោងរៀបចំជាមុន ឈ្មោះ[redacted]ណាត ហៅ ដេត បានធ្វើសកម្មភាពបើកទ្វាររថយន្តចូលក្នុងដោយអាវុធខ្លីពុំស្គាល់ម៉ាកលើឈ្មោះ[redacted] សោភា ហៅប៊ី ភេទស្រី អាយុ១៩ឆ្នាំ ខណៈពេលជនរងគ្រោះកំពុងអង្គុយក្នុងរថយន្តម៉ាកកាមរីសេរី២០០២ ពណ៌ទឹកប្រាក់ ផ្លាកលេខភ្នំពេញ២M-៨៣១៥ នៅមុំសាកលវិទ្យាល័យជាតិគ្រប់គ្រង ក្នុងសង្កាត់វត្តភ្នំ និងបង្ខំឲ្យជនរងគ្រោះបើករថយន្តចេញពីចំណុចកើតហេតុ និង បានប្តូរបើកដោយខ្លួនឯងឆ្ពោះទៅខេត្តព្រះសីហនុ ដោយបានបង្ខាំងទុកជនរងគ្រោះនៅបន្ទប់លេខ១១២ សណ្ឋាគារខ្សាច់មាស ដោយចងដៃជើង និងយកស្កុតបិទមាត់ជនរងគ្រោះ ហើយបានទូរស័ព្ទទាក់ទងម្តាយជនរងគ្រោះទារប្រាក់ចំនួន៣០០.០០០$ (សាមសិបម៉ឺនដុល្លាអាមេរិក) ។ នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១ ជនល្មើសបានទូរស័ព្ទទៅម្តាយជនរងគ្រោះម្តងទៀត និងបានទារប្រាក់ត្រឹម១៥០.០០០$(ដប់ប្រាំម៉ឺនដុល្លាអាមេរិក)ដោយកំណត់ត្រឹមម៉ោង១៨ នៅផ្សារCITY MALLភ្នំពេញ ហើយចងដៃជើង និងបិតស្កុតបិទមាត់ជនរងគ្រោះដោយជិះរថយន្តឈ្នួលមកភ្នំពេញដើម្បីទទួលប្រាក់ពីមកជួបម្តាយជនរងគ្រោះក៏ត្រូវសមត្ថកិច្ចចាប់ឃាត់ខ្លួន នៅពេលកំពុងធ្វើសកម្មភាពចំណែកជនរងគ្រោះបានរើចំណងរួចក៏ទៅប្តឹងសមត្ថកិច្ច ។ ក្រោយពីឃាត់ខ្លួនឈ្មោះ[redacted]ណាត សមត្ថកិច្ចបានរកឃើញអាវុធមួយដើមដែលធ្វើសកម្មភាព ។

## នាពេលសវនាការ

ជនជាប់ចោទឈ្មោះ[redacted]ណាត បានឆ្លើយសារភាពថា៖ កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០១១ វេលាម៉ោងមួយរសៀល ខ្ញុំបាទបានដើរកាត់មុខសួនច្បារមុខសាកលវិទ្យាល័យជាតិគ្រប់គ្រង ពេលនោះខ្ញុំបាទឃើញនារីម្នាក់អង្គុយក្នុងរថយន្តម៉ាកកាមរី ពណ៌ទឹកប្រាក់គឺពុំមានចាក់សោទ្វារឡានទេ ខ្ញុំបាទចូលទៅអង្គុយនៅកៅអីមុខផ្នែកខាងស្តាំ ខ្ញុំក៏បានដកកាំភ្លើងមិនស្គាល់ម៉ាកបង្ហាញនារីនោះ ហើយជនរងគ្រោះបានសួរខ្ញុំថា ចង់បានអ្វីឲ្យខ្ញុំយកទៅកុំធ្វើបាបគេ ខ្ញុំក៏បានឲ្យជនរងគ្រោះបើកឡានចេញ ពេលជិះទៅដល់សួនច្បារជិតកំពង់ផែមុំមាត់ទន្លេ ខ្ញុំក៏ឲ្យនាងឈប់ដោយប្តូរខ្ញុំជាអ្នកបើកវិញ ។ ខ្ញុំបានបើកឡានរហូតដល់ខេត្តព្រះសីហនុ ក៏នាំជនរងគ្រោះទៅជួលផ្ទះសំណាក់បឹងកាឡូរឈើទាល។ ជនរងគ្រោះនិយាយថា គេចង់ផ្លាស់ខោអាវខ្ញុំបានចងដៃនាងទាំងពីរជាប់ទៅនឹងចានបង្គន់ហើយយកស្កុតបិទមាត់ ខ្ញុំក៏បានចេញទៅទិញខោអាវនិងស្បែកជើង ពេលទិញបាន

Scanned by CamScanner

ហើយក៏ហូសទៅជួលបន្ទប់ក្នុងសណ្ឋាគារខ្សាច់មាសមួយបន្ទប់ ហើយក៏ត្រលប់ទៅផ្ទះសំណាក់បឹងកាឡូ ឲ្យជនរងគ្រោះផ្លាស់សំលៀកបំពាក់រួចនាំទៅហូបបាយ ។ ពេលកំពុងហូបបាយឈ្មោះសោភាបានឲ្យខ្ញុំបើកទូរស័ព្ទហើយប្អូនស្រីរបស់ឈ្មោះ[redacted] សោភា បានទូរស្ទព័មក និយាយបានបន្តិចខ្ញុំក៏បិតទូរស័ព្ទ យប់នោះខ្ញុំនិងឈ្មោះ[redacted] សោភា ដេកនៅសណ្ឋាគារខ្សាច់មាសជាមួយគ្នា ។ នៅប្រហែលម៉ោង១១យប់ ខ្ញុំបាទបានយកខ្សែចង់ដៃជើងជនរងគ្រោះនិងបិតមាត់ បន្ទាប់មកខ្ញុំយកឡានទៅទុកនៅសណ្ឋាគារផ្សេងហើយបានទូរស័ព្ទទៅម្ដាយជនរងគ្រោះទារប្រាក់ចំនួន ៣០០.០០០$ (សាមសិបម៉ឺនដុល្លាអាមេរិក) គាត់ប្រាប់ថាប្រាក់ច្រើនបែបនេះពុំមានទេ ,បន្ទាប់មកខ្ញុំបានទូរស័ព្ទម្ដងទៀតដោយទារចំនួន១៥០.០០០$(ដប់ប្រាំម៉ឺនដុល្លាអាមេរិក) ។លុះស្អែកថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១ ខ្ញុំក៏ចេញមកភ្នំពេញ តឹជិះតាក់ស៊ីដល់ត្រពាំងក្រឡឹងខ្ញុំបានទូរស័ព្ទទៅម្ដាយ[redacted] សោភា ម្ដងទៀតដោយសួរនាំរឿងប្រាក់ ហើយណាត់ទៅផ្សារស៊ីធីម៉ល ពេលទៅដល់ក៏ត្រូវសមត្ថកិច្ចឃាត់ខ្ញុំបាទតែម្ដង ។ ចំពោះអាវុធគឺខ្ញុំបាទទិញពីអ្នកលេងបាល់ជាមួយគ្នាក្នុងតម្លៃ ៥០$ (ហាសិបដុល្លារអាមេរិក) ខ្ញុំបាទមានតែម្នាក់ឯងទេ ពុំមានបក្ខពួកផ្សេងទេ ។ សំណូមពរសុំឲ្យតុលាការបន្ធូរបន្ថយទោស ។

ជនរងគ្រោះឈ្មោះ[redacted] សោភា បានឆ្លើយថាៈ ថ្ងៃកើតហេតុ ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១១វេលាម៉ោងប្រហែល១ជាងរសៀល នាងខ្ញុំឈប់ក្នុងរថយន្តនៅមុខសាលាជាតិគ្រប់គ្រង់ស្រាប់តែមានមនុស្សប្រុសម្នាក់ចូលទៅក្នុងឡានរបស់នាងខ្ញុំកៅអីមុខខាងស្ដាំដៃ ដោយដកកាំភ្លើងខ្លីភ្ជង់ហើយឲ្យនាងខ្ញុំបើកឡានទៅមុខ ។ ពេលមកដល់មាត់ទន្លេឈ្មោះ[redacted]ណាត ប្តូរទៅបើកម្ដងរួចក៏បន្តដំណើរទៅខេត្តព្រះសីហនុ ហើយបានចូលទៅផ្ទះសំណាក់បឹងកាឡូអូឈើទាល ឈ្មោះ[redacted]ណាត បានយកខ្សែមកចងដៃជើងនាងខ្ញុំ និងយកស្កុតបិតមាត់ជាប់និងចានបង្គន់ ហើយឈ្មោះវណ្ណាណាត ចេញទៅក្រៅទិញសំលៀកបំពាក់ឲ្យនាងខ្ញុំ។ វេលាម៉ោង១៩:២០នាទី ឈ្មោះវណ្ណាណាត បាននាំនាងខ្ញុំទៅហូបបាយនៅម្តុំអូឈើទាល ពេលហូបបាយរួចហើយក៏ត្រលប់មកសណ្ឋាគារវិញ ហើយឈ្មោះវណ្ណាណាត បានយកខ្សែចងដៃចងជើងនិងយកស្កុតបិតមាត់កុំឲ្យខ្ញុំស្រែក បន្ទាប់មកឈ្មោះវណ្ណាណាត ចេញទៅក្រៅបាត់ទៅ ។ លុះដល់ថ្ងៃទី២៨-០១-២០១១ ឈ្មោះវណ្ណាណាត បានចេញទៅក្រៅមិនដឹងទៅណា ទេដោយបានចងនាងខ្ញុំជាប់អស់រយៈពេលជិតពីរម៉ោងមិនឃើញត្រលប់មកវិញនាងខ្ញុំក៏បានរើបំរះរបូតខ្សែចំណងរួចទៅប្រាប់អ្នកធ្វើការផ្នែកសាកសួរពត៌មាន ហើយទូរស័ព្ទមកម្ដាយនាងខ្ញុំ និងបានប្ដឹងសមត្ថកិច្ចនៅទីនោះតែម្ដង ។ នាងខ្ញុំសុំឲ្យតុលាការផ្ដន្ទាទោសជនល្មើសតាមច្បាប់និងទាមទារជម្ងឺចិត្តពីជនល្មើសចំនួន១០.០០០$ (មួយម៉ឺនដុល្លាអាមេរិក)ពីជនជាប់ចោទ។ នាងខ្ញុំសូមបញ្ជាក់ថា ៖ ពីមុនមកពុំដែលស្គាល់ជននេះទេ ចាប់តាំងពីពេលជននេះចូលក្នុងឡាននាងខ្ញុំពេលប្តូរបើករថយន្តពេលចាក់សាំង និងស្នាក់នៅខេត្តព្រះសីហនុ នាងខ្ញុំពុំហ៊ានស្រែក ឬ រត់ព្រោះខ្លាចគេសម្លាប់។ជនល្មើសពុំបានធ្វើបាប ឬ រំលោភទេ គេចង់បានតែប្រាក់ពីម្ដាយនាងខ្ញុំតែប៉ុណ្ណោះ។

សាក្សីឈ្មោះ[redacted] ស៊ីណា បានឆ្លើយថា៖ នាងខ្ញុំត្រូវជាម្ដាយជនរងគ្រោះ នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០១១ វេលាម៉ោង១០:៣០នាទីព្រឹក កូននាងខ្ញុំបានចេញពីផ្ទះដើម្បីទៅមហាវិទ្យាល័យជាតិគ្រប់គ្រង់ ហើយម៉ោង០១:៣០នាទីរសៀលកូននាងខ្ញុំពុំឃើញត្រលប់មកផ្ទះដូចសព្វមួយដងនៅវេលាម៉ោងប្រហែល០៦ល្ងាច នាងខ្ញុំបានទូរស័ព្ទទៅកូនស្រីនាងខ្ញុំឈ្មោះ[redacted] សោភា តែមិនចូលលុះដល់ម៉ោង៧និង៣០នាទីយប់ នាងខ្ញុំបានទូរស័ព្ទទៅម្ដងទៀតចូល តែត្រូវបានឈ្មោះវណ្ណាណាតជាអ្នកលើកទូរស័ព្ទ ហើយបាននិយាយាថាវាចាប់កូនស្រីនាងខ្ញុំទៅខេត្តឆ្ងាយ ហើយវាក៏បិតទូរស័ព្ទបាត់ទៅ លុះដល់វេលាម៉ោងប្រហែល១១និង៣០នាទីយប់ វាបានទូរស័ព្ទមកនាងខ្ញុំនិយាយថា វាត្រូវ

ការប្រាក់ ចំនួន៣០០.០០០$(សាមសិបម៉ឺនដុល្លាអាមេរិក)រួចក៏បិតទូរស័ព្ទ។ មួយសន្ទុះក្រោយមកវាទូរស័ព្ទម្តងទៀត ដោយនិយាយថាវាត្រូវការប្រាក់ចំនួន១៥០.០០០$(ដប់ប្រាំម៉ឺនដុល្លាអាមេរិក) នាងខ្ញុំឆ្លើយវិញ ថានាងខ្ញុំគ្មានប្រាក់ទេ វាក៏ឆ្លើយមកវិញ បើគ្មានប្រាក់ទេស្អែកថ្ងៃត្រង់ចាំយកការសែតទៅមើលទៅរួច ក៏បិតទូរស័ព្ទបាត់ទៅ ។ លុះដល់ព្រឹកថ្ងៃទី២៨-០១-២០១១ ម៉ោងប្រហែល១០និង៣០នាទីព្រឹក វាបានទូរស័ព្ទមកនាងខ្ញុំម្តងទៀត ហើយនាងខ្ញុំឆ្លើយថានាងខ្ញុំគ្មានប្រាក់ទេ មានតែបីម៉ឺនដុល្លាអាមេរិក វាមិនព្រមក៏បិតទូរស័ព្ទ។ នៅម៉ោង១១និង៣០នាទី កូនស្រីនាងខ្ញុំឈ្មោះ [redacted] សោភា បានទូរស័ព្ទមកនាងខ្ញុំថាឲ្យមកយកវានៅខេត្តព្រះសីហនុ ។ នៅវេលាម៉ោងប្រហែល០២រសៀល ឈ្មោះ [redacted] វណ្ណណាត ទូរស័ព្ទមកនាងខ្ញុំយកប្រាក់ឲ្យវានៅផ្សារស៊ីធីម៉ លជាន់ទី២ នាងខ្ញុំក៏ទៅហើយសមត្ថកិច្ចក៏ទៅជាមួយដែរនិងចាប់បានជនល្មើសតែម្តង ។ សុំឲ្យតុលាការសម្រេចតាមច្បាប់។

ក្រឡាបញ្ជីអានអំណានចម្លើយសាក្សីឈ្មោះ [redacted] វិសាល នៅជំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ថាៈ កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០១១ វេលាម៉ោងប្រហែល១៨ : ៣៥ នាទី មានភ្ញៀវពីរនាក់បានមកជួលបន្ទប់ស្នាក់នៅសណ្ឋាគារខ្សាច់មាសបន្ទប់លេខ៥២៥ ស្នាក់នៅជាមួយគ្នា។ ភ្ញៀវពីរនាក់នោះស្រីម្នាក់ប្រុសម្នាក់ដោយប្រុសម្នាក់នោះមានមាឌស្តើងកម្ពស់ប្រហែល១,៥៥ សម្បុរសសក់បាសអាយុប្រហែល២១ឆ្នាំ ។ ពេលមកជួលបន្ទប់ម្នាក់ប្រុស ជាអ្នកជួលបន្ទប់ស្នាក់នៅ រីឯស្ត្រីម្នាក់នោះដើរតាមពីក្រោយក្នុងស្ថានភាពធម្មតាដូចភ្ញៀវឯទៀតដែរគ្មានចងដៃជើងឬបិតមាត់ទេពោលគឺទាំងពីរបង្ហាញអាកប្បកិរិយាដូចអ្នកធ្លាប់ស្គាល់គ្នា ឬគ្រួសារតែមួយដោយគ្មានបង្ហាញកាយវិការណាមួយដែលធ្វើឲ្យបុគ្គលិកសណ្ឋាគារយើងខ្ញុំមានការកត់សម្គាល់ ឬ សង្ស័យឡើយ ។

ក្រឡាបញ្ជីអានអំណានចម្លើយសាក្សីឈ្មោះ [redacted] សារ៉ាត នៅជំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ថាៈ កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០១១ វេលាម៉ោង១៨ និង១៥នាទី មានភ្ញៀវពីរនាក់(ប្រុសម្នាក់និងស្រីម្នាក់) បានបើករថយន្តម៉ាកកាមរីបាឡែន ពណ៌ទឹកប្រាក់មិនចាំស្លាកលេខទៅរកបន្ទប់ស្នាក់នៅក្នុងបឹងកាឡូអូឈើទាលដើម្បីស្នាក់នៅ ។ ពេលចូលបន្ទប់ស្នាក់នៅខ្ញុំបាទបានឲ្យភ្ញៀវសរសេរអំពីអត្តសញ្ញាណរបស់គេដោយខ្លួនឯង តែភ្ញៀវម្នាក់នោះបានសរសេរតែលេខអាយឌីឲ្យពួកខ្ញុំតែប៉ុណ្ណោះគឺលេខ ០១០០០២៧៤៥ ការចូលមកស្នាក់នៅបន្ទប់លេខ១១២ បឹងកាឡូដែលខ្ញុំធ្វើការនេះគឺពួកគេចូលទៅនៅបានប្រហែល១៥នាទី ក៏នាំគ្នាដើរចេញទៅវិញទាំងពីរនាក់ជិះរថយន្តទៅក្រៅបាត់មិនដឹងទៅណា។លុះដល់ម៉ោងប្រហែល៧ព្រឹកក៏មានមនុស្សប្រុសផ្សេងយកកូនសោរបន្ទប់មកឲ្យអ្នកទទួលវិញ ។

តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ៖ ឆ្លងតាមការសួរដេញដោលក្នុងសវនាការជនជាប់ចោទបានឆ្លើយថា៖ នៅថ្ងៃទី២៧-០១-២០១១ ខ្លួនពិតជាបានចាប់ជនរងគ្រោះឈ្មោះ [redacted] សោភា ខណៈពេលដែលជនរងគ្រោះកំពុងអង្គុយក្នុងឡានតែម្នាក់ឯងដោយយកកាំភ្លើងមិនស្គាល់ម៉ាក់ភ្ជង់គម្រាមជនរងគ្រោះយកទៅខេត្តព្រះសីហនុ ដោយមានគោលបំណងជំរិតទារប្រាក់ពីម្តាយជនរងគ្រោះឈ្មោះ [redacted] ស៊ីណា។ ពេលទៅដល់ខេត្តព្រះសីហនុ ជនជាប់ចោទឈ្មោះ [redacted] វណ្ណណាត បានបង្ខាំងជនរងគ្រោះដោយចងដៃជើងទុកក្នុងបន្ទប់សណ្ឋាគារខ្សាច់មាសខេត្តព្រះសីហនុ ហើយបានទូរស័ព្ទគម្រាមម្តាយជនរងគ្រោះទារយកប្រាក់ចំនួន ៣០០.០០០$ (សាមសិបម៉ឺនដុល្លារអាមេរិក) លុះដល់ថ្ងៃទី ២៨-០១-២០១១ ជនជាប់ចោទបានមករាជធានីភ្នំពេញដើម្បីមកទទួលប្រាក់ពីម្តាយជនរងគ្រោះនៅផ្សារស៊ីធីម៉ លក៏ត្រូវសមត្ថកិច្ចចាប់ឃាត់ខ្លួនតែម្តង ។ អំពើនេះគឺជាបទ ចាប់និងឃុំឃាំងមនុស្សដោយខុសច្បាប់ដោយមានស្ថានទម្ងន់ "ក្នុងគោលដៅជំរិតយកទ្រព្យសម្បត្តិ" និងបទកាន់កាប់

អាវុធដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅសង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ និងសង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២៧និង២៨ ខែមករា ឆ្នាំ២០១១ ហេតុដូច្នេះតំណាងអយ្យការសុំតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ ៣៥៨ អ.យ.ឃ ចុះថ្ងៃទី០៤-៣-២០១១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញទុកជាបានការពេញទាំងមូល និងប្តឹងទៅក្រុមប្រឹក្សាជំនុំជម្រះផ្តន្ទាទោសជនល្មើសតាមច្បាប់ ។

លោក [redacted]ម្កា ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា៖ បន្ទាប់ពីបានសួរដេញដោលក្នុងសវនាការ ឃើញថាកូនក្តីខ្ញុំបាទឈ្មោះ [redacted] វណ្ណណាត ឆ្លើយសារភាពនូវទោសកំហុសរបស់ខ្លួននៅគ្រប់ដំណាក់កាលនីតិវិធី ហេតុដូច្នេះក្នុងនាមខ្ញុំបាទជាមេធាវីការពារឲ្យឈ្មោះ[redacted] វណ្ណណាត សុំឲ្យក្រុមប្រឹក្សាជំនុំជម្រះបន្ធូរបន្ថយទោសដល់កូនក្តីខ្ញុំបាទដោយក្តីអនុគ្រោះ ។ ដោយហេតុថាអំពើប្រព្រឹត្តរបស់កូនក្តីខ្ញុំបាទ ជាសើកទី២ ហើយជនរងគ្រោះក៏ពុំមានគ្រោះថ្នាក់អ្វីទេ ជនរងគ្រោះហាក់ដូចត្រូវរ៉ូវគ្នាជាមួយកូនក្តីខ្ញុំបាទ គាត់ពុំរត់ទេ ថែមទាំងប្រាប់ឲ្យកូនក្តីខ្ញុំទូរស័ព្ទទៅម្តាយរបស់នាងដើម្បីទារប្រាក់ទៀត។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយជនរងគ្រោះ និង ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់អំណានចម្លើយនិងចម្លើយសាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យឯកសារពាក់ពន្ធ័នៅក្នុងសំណុំរឿង

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## <u>សាលាដំបូងរាជធានីភ្នំពេញ</u>

## <u>យល់ឃើញថា</u>

-តាមដីកាសន្និដ្ឋានស្ថាពរលេខ៥៨អ.យ.ឃ ចុះថ្ងៃទី០៤-៣-២០១១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងដីកាសម្រេចបញ្ជូនសំណុំរឿងទៅជម្រះលេខ ៨១៥ ជ.ជ.រ ចុះថ្ងៃទី២១-៣-២០១១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចបញ្ជូនជនជាប់ចោទឈ្មោ[redacted] វណ្ណណាត ហៅ ដេត ភេទប្រុស អាយុ២៩ឆ្នាំ ពីបទ ការចាប់និងបង្ខាំងមនុស្សដោយខុសច្បាប់ដោយមានស្ថានទម្ងន់ "ក្នុងគោលដៅជំរិតយកទ្រព្យសម្បត្តិ" និងបទកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅសង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ និង សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២៧និង២៨ ខែមករា ឆ្នាំ២០១១ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា២៥៣ ,២៥៤ និងមាត្រា៤៩០ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

-តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ[redacted] វណ្ណណាត ហៅ ដេត បានបញ្ជាក់ថា៖ នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០១១ វេលាម៉ោង១ និង ៣០នាទី ខ្លួនពិតជាបានយកកាំភ្លើងប្លន់នារីរងគ្រោះទារប្រាក់ នៅមុខសាកលវិទ្យាល័យជាតិគ្រប់គ្រង ដោយមុនដំបូងខ្លួនឃើញនារីរងគ្រោះអង្គុយក្នុងរថយន្តម្នាក់ឯងដោយមិនបានចាក់សោទ្វាររថយន្តទេ ខ្លួនក៏បើកទ្វារចូលទៅអង្គុយក្នុងរថយន្តរួចដកកាំភ្លើងបង្ហាញជនរងគ្រោះ និងបានឲ្យជនរងគ្រោះបើកចេញទៅសួនច្បារកោះទន្លេហើយខ្លួនក៏ប្តូរមកបើកឆ្ពោះទៅខេត្តព្រះសីហនុ ។ ពេលទៅដល់ខេត្តព្រះសីហនុ ខ្លួនបានទៅស្នាក់នៅផ្ទះ

សំណាក់បឹងកាឡូអូរឈើទាលរួចប្តូទៅសណ្ឋាគារខ្សាច់មាសវិញ បន្ទាប់មកខ្លួនបានទូរស័ព្ទជំរិតប្រាក់ទារពីម្តាយជនរងគ្រោះចំនួន៣០០.០០០$ (សាមសិបម៉ឺនដុល្លាអាមេរិក) ។ លុះដល់ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១ ខ្លួនក៏ចេញមកភ្នំពេញ ដើម្បីយកប្រាក់ពីម្តាយជនរងគ្រោះនៅផ្សារស៊ីធីម៉ល តែត្រូវម្តាយជនរងគ្រោះប្តឹងសមត្ថកិច្ចចាប់ខ្លួនតែម្តង។ ចំពោះអាវុធខ្លួនបានទិញពីអ្នកលេងបាលជាមួយគ្នាតម្លៃ៥០$ ហើយអាវុធនេះខ្លួនបានយកទៅលាក់នៅផ្ទះរបស់ខ្លួន។

តាមចម្លើយរបស់ជនរងគ្រោ[redacted]សោភា ថា ៖ ខ្លួនមិនដែលស្គាល់ឈ្មោះ [redacted] វណ្ណណាត ទេ នៅថ្ងៃកើតហេតុទី២៧ ខែមករា ឆ្នាំ២០១១ វេលាម៉ោងប្រហែល១ និង ៣០នាទី ខ្លួនកំពុងអង្គុយក្នុងឡានរង់ចាំមិត្តភ័ក្ក ស្រាប់តែមានបុរសម្នាក់បានចូលក្នុងឡានខ្លួន ហើយបង្ហាញកាំភ្លើងមិនស្គាល់ម៉ាក ហើយបានឲ្យខ្លួនការបើកឡានទៅមុខ ពេលបើកដល់មាត់ទន្លេ ក៏ប្តូរទៅបើកវិញ និងបន្តឆ្ពោះទៅខេត្តព្រះសីហនុ ។ ពេលដល់ខេត្តព្រះសីហនុ ឈ្មោះ[redacted] វណ្ណណាត បាននាំខ្លួនទៅផ្ទះសំណាក់បឹងកាឡូអូរឈើទាលរួចក៏ទៅជួលបន្ទប់បន្តនៅសណ្ឋាគារខ្សាច់មាស ពេលជួលបន្ទប់នៅសណ្ឋាគារខ្សាច់មាស ឈ្មោះ[redacted]វណ្ណណាត ចាប់ចងដៃចងជើងនិងយកស្កុតបិតមាត់ទុកក្នុងបន្ទប់សណ្ឋាគារ ។ លុះដល់ថ្ងៃទី២៨ ខែ មករា ឆ្នាំ២០១១ វេលាម៉ោង១១ព្រឹក ទើបខ្លួនរើស្រាយចំណងរួចហើយក៏ប្តឹងសមត្ថកិច្ច។ឈ្មោះ[redacted] វណ្ណណាត ពិតជាពុំដែលស្គាល់ទេ បានជាពុំហ៊ានរត់ ព្រោះខ្លាចគាត់សម្លាប់ ពេលនៅបន្ទប់គាត់ពុំបានរំលោភទេ ។

-តាមចម្លើយសាក្សីឈ្មោះ[redacted] ស៊ីណា បានឆ្លើយបំភ្លឺថា៖ ខ្លួនត្រូវជាម្តាយរបស់ជនរងគ្រោះ ជារៀងរាល់ថ្ងៃកូនខ្លួនចេញពីសាលាវិញនៅម៉ោង១ និង ៣០នាទី នៅថ្ងៃកើតហេតុ មិនឃើញកូនស្រីខ្លួនត្រលប់មកផ្ទះទេ ។ លុះដល់វេលាម៉ោង៦ល្ងាចខ្លួនបានទូរស័ព្ទទៅកូនស្រីខ្លួន តែទូរស័ព្ទមិនចូល រហូតដល់ម៉ោង៧និង៣០នាទី ទើបទូរស័ព្ទចូល ប៉ុន្តែបុរសជាអ្នកទទួល ហើយបាននិយាយថា វាចាប់កូនស្រីខ្លួនទៅខេត្តឆ្ងាយ ហើយក៏បិតទូរស័ព្ទ រហូតដល់ម៉ោង១១ និង ២០នាទីយប់ ឈ្មោះ[redacted] វណ្ណណាត បានទូរស័ព្ទមកខ្លួនជំរិតទារប្រាក់ចំនួន៣០០.០០០$ (សាមសិបម៉ឺនដុល្លាអាមេរិក) ទើបដោះលែងកូនស្រីខ្លួន , មួយសន្ទុះក្រោយមកក៏បានទូរស័ព្ទមកម្តងទៀតដោយទារប្រាក់ចំនួន១៥០.០០០$ (ដប់ប្រាំម៉ឺនដុល្លាអាមេរិក) ខ្លួនតបវិញថាខ្លួនគ្មានប្រាក់ទេ ។ ស្អែកព្រឹកនៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១ វេលាម៉ោងប្រហែល១១ និង៣០នាទី កូនស្រីខ្លួនបានទូរស័ព្ទមកខ្លួនថាឲ្យមកយកវានៅខេត្តព្រះសីហនុ , នៅវេលាម៉ោង០២រសៀល ឈ្មោះ[redacted]វណ្ណណាត បានទូរស័ព្ទមកខ្លួនឲ្យយកប្រាក់ទៅឲ្យវានៅផ្សារស៊ីធីម៉លជាន់ទី២ ហើយសមត្ថកិច្ចចាប់ខ្លួនវាបាននៅផ្សារស៊ីធីម៉លតែម្តង ។

-ចម្លើយសាក្សីឈ្មោ[redacted]សោល និងឈ្មោះ[redacted] សាវ៉ាត បានឆ្លើយប្រហាក់ប្រហែលគ្នាពិតជាបានឃើញជនជាប់ចោទឈ្មោ[redacted]ណ្ណណាត និងជនរងគ្រោះឈ្មោ[redacted] សោភា ទៅជួលបន្ទប់ស្នាក់នៅជាមួយគ្នាក្នុងខេត្តព្រះសីហនុប្រាកដមែន ។

-ចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ[redacted] វណ្ណណាត ហៅ ដេត ,ចម្លើយជនរងគ្រោះឈ្មោះ[redacted] សោភា និង ចម្លើយសាក្សីឈ្មោ[redacted] ស៊ីណា ម្តាយជនរគ្រោះមានភាពស៊ីសង្វាក់គ្នាដែលអាចឲ្យតុលាការជឿបានថា ជនជាប់ចោទឈ្មោះ[redacted] វណ្ណណាត ហៅ ដេត ពិតជាចាប់ជនរងគ្រោះឈ្មោះ [redacted] សោភា ក្នុងគោលបំណងជំរិតទារប្រាក់ពីម្តាយជនរងគ្រោះពិតប្រាកដមែន អំពើនេះគឺមានធាតុផ្សំគ្រប់គ្រាន់ជាបទ ការចាប់និងបង្ខាំងមនុស្សដោយខុសច្បាប់ដោយមានស្ថានទម្ងន់ "ក្នុងគោលដៅជំរិតយកទ្រព្យសម្បត្តិ" និងបទកាន់កាប់អាវុធដោយគ្មានការអនុញ្ញាតិប្រព្រឹត្តនៅសង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ និង សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្ត

ព្រះសីហនុ កាលពីថ្ងៃទី ២៧និង២៨ ខែមករា ឆ្នាំ២០១១ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា២៥៣,២៥៤ និង មាត្រា៤៩០នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

-អំពើរបស់ជនជនជាប់ បានធ្វើឲ្យប៉ះពាល់ដល់សន្តិសុខសណ្តាប់ធ្នាប់និងរបៀបរៀបរយសាធារណៈក្នុងសង្គម ដែលច្បាប់តម្រូវឲ្យផ្តន្ទាទោសដូចមានចែងក្នុងបញ្ញតិមាត្រា២៥៣,២៥៤ និង មាត្រា៤៩០នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

បទល្មើសនេះគឺជាបទល្មើសជាក់ស្តែងដែលសមត្ថកិច្ចឃាត់ខ្លួនតឺជនល្មើសបានកំពុងតែធ្វើសកម្មភាពទៅទទួលប្រាក់ពីម្តាយជនរងគ្រោះនៅផ្សារស៊ីធីម៉ល ។

-ជនជាប់ចោទជានីតិជន មានសមត្ថភាពគ្រប់គ្រាន់ ដឹងពីការប្រព្រឹត្តនូវអំពើរបស់ខ្លួនហើយត្រូវតែទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ និងសំណងជួសជុលការខូចខាត ។

-វត្ថុតាងចាប់យករួមមាន៖

ក/កាំភ្លើងខ្លីមួយដើមមិនស្គាល់ម៉ាក់ ,បង់មួយមានចំនួនពីរគ្រាប់ ,ស្កត់សំរាប់បិតមាត់ចំនួនពីរបន្ទះ និងខ្សែចំណងរុត(ខ្សែសៀល) មិនប្រើចំនួន៣១ខ្សែ និងប្រើរួចចំនួនបួនខ្សែ គប្បីរឹបអូសនិងបំផ្លាញចោល ។

ខ/ ទូរស័ព្ទមួយគ្រឿងម៉ាក់NOKIA C6 មានស៊ីម ,ស្បែកជើងមួយគូរ ,កាបូបក្រណាត គប្បីប្រគល់ឲ្យម្ចាស់ដើមវិញ ។

- សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ សុំបន្ធូបន្ថយលើកូនក្តីខ្លួន គប្បីពិចារណាតាមច្បាប់។

មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] វណ្ណណាត ហៅ ដេត ពីបទកាប់ចាប់និងបង្ខាំងមនុស្សដោយខុសច្បាប់ដោយមានស្ថានទម្ងន់ "ក្នុងគោលដៅជំរិតយកទ្រព្យសម្បត្តិ" និងបទកាន់កាប់អាវុធដោយគ្មានការអនុញ្ញាតិ ប្រព្រឹត្តនៅសង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ និង សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២៧,២៨ ខែមករា ឆ្នាំ២០១១ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា២៥៣,២៥៤និងមាត្រា៤៩០ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

-ជនរងគ្រោះទាមទារសំណងជម្ងឺចិត្តចំនួន១០.០០០$ (មួយម៉ឺនដុល្លាអាមេរិក) គប្បីតុលាការពិចារណា ។

## ហេតុដូច្នេះសាលាដំបូងរាជធានីភ្នំពេញ

## សម្រេច

I. ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] វណ្ណណាត ហៅ ដេត ភេទប្រុស អាយុ២៩ឆ្នាំ (មានសារតាជាតិខាងលើ) ដាក់ពន្ធនាគារកំណត់ ១៥ឆ្នាំ (ដប់ប្រាំឆ្នាំ) និងពិន័យជាប្រាក់ចំនួន ១.០០០.០០០រៀល (មួយលានរៀល) ពីបទការចាប់និងបង្ខាំងមនុស្សដោយខុសច្បាប់ដោយមានស្ថានទម្ងន់ "ក្នុងគោលដៅជំរិតយកទ្រព្យសម្បត្តិ" និងបទកាន់កាប់អាវុធដោយគ្មានការអនុញ្ញាតិ ប្រព្រឹត្តនៅសង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ និង សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពី ថ្ងៃទី ២៧,២៨ ខែមករា ឆ្នាំ២០១១ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា២៥៣,២៥៤និង មាត្រា៤៩០ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

II, វត្ថុតាងចាប់យករួមមាន ៖

ក/កាំភ្លើងខ្លីមួយដើមមិនស្គាល់ម៉ាក់,បង់មួយមានចំនួនពីរគ្រាប់ ,ស្កត់សំរាប់បិតមាត់ចំនួនពីរបន្ទះ ,ខ្សែចំណងរុត (ខ្សែសៀល) មិនប្រើចំនួន៣១ខ្សែ និងប្រើរួចចំនួនបួនខ្សែ រឹបអូសនិងបំផ្លាញចោល ។

ខ/ ទូរស័ព្ទមួយគ្រឿងម៉ាក់NOKIA C6 មានស៊ីម, ស្បែកជើងមួយគូរ ,កាបូបក្រណាត់ ត្រូវប្រគល់ឲ្យម្ចាស់ដើមវិញ ពេលសាលក្រមនេះចូលជាស្ថាពរ ។

III , បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] វណ្ណណាត សងជម្ងឺចិត្តចំនួន១០,០០០, ០០០រៀល (ដប់លានរៀល) ឲ្យទៅជនរងគ្រោះនិងជាដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សោភា ទាមទារលើសពីនេះបដិសេធចោល ។

IV សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី២១-៩-២០១១ ចំពោះមុខជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈថ្ងៃទី០៦-១០-២០១១ បើកផ្លូវប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| | | [redacted] | |

Scanned by CamScanner